## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០១៧៤ អបស.មគ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៨

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជម្រាបមក**

**-ឯកឧត្តម អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត**

**-លោក លោកស្រី ប្រធានមន្ទីរពេទ្យជាតិ**

**-លោក លោកស្រី ប្រធានមជ្ឈមណ្ឌលជាតិ**

**-លោក លោកស្រី ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត**

**-គ្រប់សេវាព្យាបាលនៅតាមឯកជនទាំងអស់**

កម្មវត្ថុ: ស្តីពីការមិនអនុញ្ញាតឲ្យធ្វើការផ្សាំ ឬជួញដូរកោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិត (ញីឬឈ្មោល) ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។

យោង:
-ព្រះរាជក្រមលេខ នស/រកម/០៨១៦/០១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង លើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។
-ប្រកាសលេខ ៦៧៩ ប្រក/ស.នក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង ឈាម មេជីវិត ខួរឆ្អឹង និង កោសិកាដើមរបស់មនុស្ស។
-ប្រកាសលេខ ៦៨៤ អបស.មព ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រង ត្រួតពិនិត្យ និងអនុញ្ញាតដល់មន្ទីរពេទ្យ និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ក្នុងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ក្រសួងសុខាភិបាលសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងគ្រប់ សេវាព្យាបាលឯកជនទាំងអស់ជ្រាបថា ធ្វើការផ្សាំ ឬជួញដូរ កោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិត (ញីឬឈ្មោល) ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល ហើយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់ត្រូវអនុវត្តអោយបានត្រឹមត្រូវទៅតាមលិខិតបទដ្ឋានគតិយុត្តព្រមទាំងច្បាប់ដែលមានជាធរមានដើម្បីជៀសវាងការប្រឈមមុខទៅនឹងផ្លូវច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងគ្រប់សេវាព្យាបាលនៅតាមឯកជនទាំងអស់ ផ្សព្វផ្សាយ និងអនុវត្តស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងគ្រប់សេវាព្យាបាលនៅតាមឯកជនទាំងអស់ ទទួលនូវការរាប់អានអំពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

វេជ្ជ. តែ គួយស៊ាន

ចម្លងជូន:
-ខុទ្ទកាល័យក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-គ្រប់គណៈវិជ្ជាជីវៈសុខាភិបាលជាតិ
-ឯកសារ កាលប្បវត្តិ